ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៣-០២-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣៨ ស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **ចៅ ភិរុណ** ជា **ឧកញ៉ា** ៤៨៦

១៥-៣-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៥ ស្តីពីការតែងតាំងឯកឧត្តម **យក់ ឌុំយ** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ៤៨៧

១៧-៣-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៦ ស្តីពីការតែងតាំងឯកឧត្តម **ជុំច សំភី** ជាសមាជិកក្រុមអ្នកច្បាប់ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៤៨៨

១៧-៣-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៧ ស្តីពីការតែងតាំងឯកឧត្តម **សុខ សាយ** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **សំ សាន** ដែលត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មី ៤៨៩

១៧-៣-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៣០៤/០៤៨ ស្តីពីការប្រោសព្រះរាជទានចំពោះ ឧកញ៉ា **លី សាយឃាង** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៤៩០


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


២២-៣-២០០៤ -អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអាយស៊ីអេស ៤៩១

១៥-៣-២០០៤ -អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ( កាំសាប) ៤៩៤

១៦-៣-២០០៤ -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៦

១៦-៣-២០០៤ -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៧

១៦-៣-២០០៤ -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៨

១៦-៣-២០០៤ -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៩

១៦-៣-២០០៤ -អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០០

| | | |
|---|---|---|
| ១៧-៣-២០០៤ | -អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥០១ |
| ២២-៣-២០០៤ | -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៥០២ |
| ២២-៣-២០០៤ | -អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥០៣ |
| ២២-៣-២០០៤ | -អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ៥០៤ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៥០៥ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៥០៧ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥០៨ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥០៩ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១០ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១២ |
| ២៣-៣-២០០៤ | -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១៣ |

## ១-សេចក្តីសំរេច

| | | |
|---|---|---|
| ១៩-៣-២០០៤ | -សេចក្តីសំរេច លេខ ១១ សសរ ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៧ | ៥១៤ |
| ២៣-៣-២០០៤ | -សេចក្តីសំរេច លេខ ១២ សសរ ស្តីពីការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម | ៥១៦ |

## II-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

| | | |
|---|---|---|
| ២៣-៣-២០០៤ | -សេចក្តីសំរេចលេខ ០០៣/០៤ គ.ជ.ប ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា ចេញពីមណ្ឌលខេត្ត កំពង់ចាម | ៥១៩ |
| ២៣-៣-២០០៤ | -សេចក្តីប្រកាសលេខ ០០៤/០៤ គ.ជ.ប ស្តីពីការទទួលស្គាល់ឯកឧត្តម **ខឹន គឹមស្រេង** តំណាងរាស្ត្រ លំដាប់ទី ៩ របស់គណបក្សប្រជាជនកម្ពុជា នៅមណ្ឌលខេត្ត កំពង់ចាម | ៥២០ |

# ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៣៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅ ភិរុណ

ជា

## ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

ទូលព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

លេខៈ ៣៥ ចល

ជា ស៊ីម

៣៤.០៤-០២.០៣៤ ដើម្បីចម្លងចែក

រាជធានីភ្នំពេញៈ ថ្ងៃទី ២២ ខែ មិនា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សារី តារ៉

ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម យត់ ខុំយ ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

លេខ: ៣៣ ចលេ ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤០.០៤.០៣.០៤៥

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំង ឯកឧត្តម ដួង សំគី ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ក្នុងឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២.-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

អគ្គលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤.០៣.០៤៦

លេខ: ៣៤ ទ.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ២០០៤

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

[signature]

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៣០៤/០៤៧

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តម សួន សាយ ជាទីប្រឹក្សាសម្តេចផ្ទាល់ ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម សំ សាន ដែលត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មី ។

**មាត្រា២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៤
ជូនព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ៣១ ច.ល
៣ល.០៤.០៣.០៤៧
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឧនាពី ឆាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៤/០៨៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី )

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា លី សាយយាង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
លេខៈ ៣២ ច.ល
**ជា ស៊ីម**

៣រល-០៤.០៣.០៨៨
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈិនឌី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ២៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យអាយស៊ីអេស

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោកស្រី ឃួន សុដារី ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
- បានឃើញយោបល់ របស់ក្រសួងអប់រំ យុវជន និងកីឡា

## ស ំ រ េ ច

**មាត្រា ១** : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យអាយស៊ីអេស** " ICS University " ហៅកាត់ជាភាសាខ្មែរ " ស.អ.ស.អ." និង ហៅកាត់ជាភាសាអង់គ្លេស

" I.C.S.U." ។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ ១៨ ផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ២** : សាកលវិទ្យាល័យអាយស៊ីអេស ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣** : សាកលវិទ្យាល័យអាយស៊ីអេស ធ្វើការបណ្តុះបណ្តាល :

- ជំនាញបច្ចេកទេសរយៈពេលខ្លី ។
- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យអាយស៊ីអេស ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤** : សាកលវិទ្យាល័យអាយស៊ីអេស មានមហាវិទ្យាល័យចំនួន ០៦ និង វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសមួយ :

- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង ភាសាបរទេស
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និង នីតិសាស្ត្រ
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជសាស្ត្រ
- មហាវិទ្យាល័យអប់រំ និង ទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម
- វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬ ប្រភេទបណ្តុះ-បណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥** : សាកលវិទ្យាល័យអាយស៊ីអេស មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេចលើគោល-នយោបាយ ផែនការអភិវឌ្ឍ អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦** : សាកលវិទ្យាល័យអាយស៊ីអេស ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការទទួលសិស្ស-និស្សិត ឱ្យចូលរៀន។

**មាត្រា ៧** : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកមកបំរើការងារ ។

- គ្រប់គ្រងឱ្យបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាមច្បាប់ និង បទដ្ឋានណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាឱ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៨** : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យអាយស៊ីអេស និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យអាយស៊ីអេស ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាល័យអាយស៊ីអេស មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តតាមអនុក្រឹត្យនេះ ។

**មាត្រា ១០** : អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៤ ខែ ០២ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

  "ដើម្បីជ្រាប"

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល

## សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ ( កាំសាប )

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស /រកម / ០៦៩៦ /០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ /០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ. បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ ( កាំសាប )

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សំរេច

**មាត្រា ១.-** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរសំរាប់អាណត្តិទី២ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឡោង ធនយុទ្ធា** | តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ជាប្រធាន |
| ២-ឯកឧត្តម | **រស់ វណ្ណា** | អគ្គនាយកសហគ្រាសសាធារណៈកាំសាប | ជាសមាជិក |
| ៣-លោក | **ឃុយ ហៀង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤-លោក | **នេត មុន្នី** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-លោក | **ស៊ាង ម៉ិនឈាង** | តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦-លោក | **ឆេង សារឿន** | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៧-លោក | **ញាន សុគុល** | តំណាងនិយោជិតសហគ្រាសសាធារណៈកាំសាប | ជាសមាជិក |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ០២ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...១៤១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៦ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន និ ងចលនាដឹកនាំពុទ្ធបរិស័ទ ចូលរួមជួយកសាងព្រះវិហារ វត្តព្រះនង្គ័ល ស្ថិតនៅក្នុងឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាម ខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ស៊ាង សួន** ព្រះចៅអធិការវត្តព្រះនង្គ័ល បច្ច័យ ២៣.៨០០ USD
២-ព្រះភិក្ខុ **អែម គីមហាក់** គង់នៅវត្តព្រះនង្គ័ល បច្ច័យ ១៦.៩២៥ USD
៣-ព្រះភិក្ខុ **អែម គីមហៀង** គង់នៅវត្តព្រះនង្គ័ល បច្ច័យ ១៥.៥០០ USD
៤-លោក **យឹម សុផាត** នាយកក្រុមហ៊ុន នៃតជ្រល ម៉ាញ អ៊ិនដាសស្ទ្រី អ៊ិនវេសមេន ថវិកា១០០.៣៧៥ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក **អ៊ាប ឈង** និងឧបាសិកា **អាំង គីមឡាន់** ថវិកា ៨.៥០០ USD
២-ឧបាសក **អុង ហុកស៊ុន** និងឧបាសិកា **អាំង ម៉ាតប៊ី** ថវិកា ៨.២០០ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៤៥ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ចការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនមន្ត្រី នៃ ក្រុមប្រឹក្សាគំរោងកែលំអ ល័ក្ខខ័ណ្ឌ ការងារ ក្នុងវិស័យកាត់ដេរកម្ពុជា (*ILO*) ចំនួន ០២រូប ដែលបានសហការល្អជាមួយក្រសួង សង្គមកិច្ច ការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ក្នុងការគ្រប់គ្រង កែលំអ មុខរបរកាត់ដេរ នៅកម្ពុជា អោយឈានទៅរកភាពរីកចំរើន ស្របតាមច្បាប់ការងារ និង អភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយ ចិរភាព ដូចមាននាមខាងក្រោម :-

១-លោក *Lejo Sibbel* ប្រធានទីប្រឹក្សាបច្ចេកទេស នៃគំរោងកែលំអ ល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យ កាត់ដេរ នៅកម្ពុជា ។

២-លោក **ឌុន សោភ័ណ** ជំនួយការ នៃ គំរោងកែលំអ ល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យកាត់ដេរ នៅកម្ពុជា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង សង្គមកិច្ចការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

151

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ជូន ***Mr.Masami Kai*** អ្នកស្ម័គ្រចិត្ត នៃ អង្គការ ***CARE*** ដែលបានផ្តល់ថវិកា ចំនួន ៧.២០៩ ដុល្លារអាមេរិក សំរាប់ជួយកសាងមជ្ឈមណ្ឌលសិក្សាវប្បធម៌កម្ពុជា-ជប៉ុន នៅស្រុកលើកដែក ខេត្តកណ្តាល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១ :** ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការផ្តល់ជំនួយ ជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់អគារសិក្សា នៅខេត្តព្រៃវែង កំពង់ស្ពឺ និង ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ ដល់ឆ្នាំសិក្សា ២០០៣-២០០៤ មានអគារសិក្សា ចំនួន ១៣៨ ខ្នង ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៩.២៧៦.០៦៧ ដុល្លារ ដូចមាននាមខាងក្រោម :-

១-អង្គការ *Aeon Group*

២-*Japan Committee for UNICEF*

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

140

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ហាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ហាបនាជាតិ** ជូនសប្បុរសជន ជប៉ុន ចំនួន ០២រូប ដែលបានផ្តល់ជំនួយ ជាថវិកា សរុប ចំនួន ១២០.០០០ ដុល្លារ សំរាប់ជួយដល់ សិស្សានុសិស្សក្រីក្រ នៅសាលាបឋមសិក្សា នៃ កំពង់សាលាទាំងបី ក្នុងស្រុកលើកដែក ខេត្តកណ្តាល ដូចមាននាមខាងក្រោម :-

១-*Mr. Satoshi TAMAKUMA* មកពី អង្គការឃែរ ជប៉ុន

២-*Ms. Sharon Wilkinson* មកពី អង្គការឃែរ ជប៉ុន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្ត កណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៤៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

### ស ំ រេ ច

**មាត្រា១** : ត្រូវបានតែងតាំងលោក **ម៉ិច លាងហ៊ី** ជាប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាល នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ-សាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៧ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយការងារ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

**សំ រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនឥស្សរជនបរទេសចំនួន ០៤ រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការសហការបំពេញការងារមនុស្សធម៌ ជាមួយកាកបាទក្រហមកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-Mr. **Kalevi Johannes Kiviso** | ប្រធានកាកបាទក្រហមហ្វាំងឡង់ |
| ២-Mr. **Ray Worner** | ទីប្រឹក្សានៃកម្មវិធីប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះ |
| ៣-Mr. **Marc Hermant** | នាយកនៃអង្គការជនពិការអន្តរជាតិ ( HI ) |
| ៤-Ms. **Tianji Dicken** | អ្នកស្ម័គ្រចិត្តតាមកម្មវិធី Australian Youth Ambassador |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង ប្រធានកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

**សំរេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានឧបត្ថម្ភប្រព័ន្ធថាមពលព្រះអាទិត្យ រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា នៅតាមមូលដ្ឋានមួយចំនួន ក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **យ៉ូស៊ីគី តាកេអូកា** (Mr *YOSHIKI TAKEOKA*) ប្រធានក្រុមហ៊ុន *KANEKA* ប្រទេសជប៉ុន បានឧបត្ថម្ភ ឧបករណ៍សំភារៈ ថាមពលព្រះអាទិត្យ នៅស្ថានកំពង់រាំង និង ស្ថានដើមស្តៅ ចំណាយអស់ទឹកប្រាក់ចំនួន ១២.៦០០ ដុល្លារ ។

២-លោក **ស៊ូ ឈុលស៊ីន** (Mr *SOO CHUL SHIN*) ប្រធានសាជីវកម្ម *POSCON Corporation* សាធារណរដ្ឋកូរ៉េ ជួយឧបត្ថម្ភ ថវិកា ចំនួន ១១.៣០០ ដុល្លារ សំរាប់អនុវត្ត នូវទីតាំង វិទ្យាល័យ សម្តេច ហេង សំរិន សាលាបឋមសិក្សា ចំណោម ស្ថានបាកឃើ ស្ថានបឹងគ្រួម និង មណ្ឌលសុខភាព ឃុំពាមកោះស្នា ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល . អភិបាលខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និង ខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ
## ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ទោ **សែម ជា** អត្តលេខ ០៤៨១ ស្នងការរង និងជាប្រធានសេនាធិការដ្ឋាន នៃស្នងការដ្ឋាននគរបាលក្រុងប៉ៃលិន ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- កាលប្បវត្តិ - ឯកសារ

